# ក្រុមមេធាវីការពារក្តីរបស់លោក អោ អាន
# AO An Defence Team

**ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-May-2020, 14:35
CMS/CFO: Sann Rada

**ផ្ញើជូន៖** ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម **C.N. JAYASINGHE**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Florence Ndepele MUMBA**
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម **Maureen HARDING CLARK**
ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖** លោកស្រី ជា លាង សហព្រះអាជ្ញាជាតិ
លោកស្រី **Brenda HOLLIS** សហព្រះរាជអាជ្ញាអន្តរជាតិ
មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/០២

***កម្មវត្ថុ÷ ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង***

**សូមគោរពលោកប្រធាន គង់ ស្រ៊ីម និងចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលជាទីគោរព**

សហមេធាវីការពារក្តី អោ អាន (*"មេធាវីការពារក្តី"*) ឆ្លើយតបទៅនឹង*បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង (បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ)*[1]។ យោងតាមហេតុផលដូចបានលើកឡើងនៅក្នុងលិខិតនេះ មេធាវីការពារក្តីសូមធ្វើការឆ្លើយតបថា អង្គជំនុំជម្រះតុលាការកំពូល ពុំទាន់បានទទួលសំណុំរឿង ០០៤/០២ តាមផ្លូវច្បាប់នៅឡើយទេ ហេតុដូច្នេះ វាពុំសមស្របឡើយក្នុងការធ្វើទំនាក់ទំនងជាមួយអង្គជំនុំជម្រះតុលាការកំពូលអនុលោមតាមសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំ

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.វ.ត.ក *បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង (បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ)* ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២០។

ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ជាបញ្ហាបឋម មេធាវីការពារក្ដីកត់សម្គាល់ថា នៅក្នុងបណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ភាពជាប់គាំងបច្ចុប្បន្ននៅក្នុងសំណុំរឿង ០០៤/២ បណ្ដាលមកពីកង្វះឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ[2]។ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានផ្ដល់ភ័ស្ដុតាងគាំទ្រចំពោះការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរទាំងនេះទេ។ មេធាវីការពារក្ដីសូមអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិគួរតែត្រូវបានបង្គាប់ឲ្យដាក់បង្ហាញភ័ស្ដុតាងដែលលោកស្រីយកមកធ្វើជាសំអាង ឬជាជម្រើសម៉្យាងទៀត ដកចេញវិញនូវទឡ្ហីករណ៍របស់លោកស្រី ស្ដីពីភាពអាចទទួលយកបាន និងនៅក្នុងមូលដ្ឋាននៃបណ្ដឹងសារទុក្ខ ដោយផ្អែកលើការចោទប្រកាន់ទាំងនេះ។

មេធាវីការពារក្ដីសូមគោរពស្នើសុំ អង្គជំនុំជម្រះតុលាការកំពូល ច្រានចោល *បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ឬ បើមិនដូច្នោះទេ ប្រកាសថា បណ្ដឹងសារទុក្ខនោះមិនអាចទទួលយកបាន និងពុំមានខ្លឹមសារអ្វីឡើយ យោងតាមហេតុផលដូចខាងក្រោមនេះ៖

ក. *បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* មិនអាចទទួលយកបានយោងតាមវិធាន ១០៥(៤)(ក) នៃវិធានផ្ទៃក្នុង;

ខ. *បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* មិនអាចទទួលយកបានយោងតាមយុត្តាធិការដែលអង្គជំនុំជម្រះតុលាការកំពូល មានជាប់មកជាមួយ។

គ. អង្គជំនុំជម្រះសាលាដំបូង ពុំ "មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០៤/០២ ដោយសារខកខានមិនបានប្ដឹងសំណុំរឿងទៅជំនុំជម្រះ" ហេតុដូច្នេះ មិនមានកំហុសអង្គច្បាប់។

ឃ. អង្គជំនុំជម្រះសាលាដំបូង ពុំមានចំណុចដែលត្រូវយកមកវិនិច្ឆ័យចំពោះមុខ ដែលតម្រូវឲ្យអនុវត្តយុត្តាធិការ ដែលជំនុំជម្រះសាលាដំបូងមានជាប់មកជាមួយ ហេតុដូច្នេះ ពុំមានកំហុសអង្គច្បាប់ ឬបំពានឆន្ទានុសិទ្ធិ។

ង. អង្គជំនុំជម្រះសាលាដំបូង ពុំមានកំហុសអង្គច្បាប់ ឬ បំពានឆន្ទានុសិទ្ធិ តាមការចោទប្រកាន់ថា បានបន្ថែមវិធានការរដ្ឋបាលដែលពុំមែនជាលក្ខខណ្ឌតម្រូវពីមុន"។ និង

ច. អង្គជំនុំជម្រះសាលាដំបូង ពុំមានកំហុសអង្គច្បាប់ និង "ពុំមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី

---

[2] *បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ៤៦, ៤៨, ជើងទំព័រ ៦៩, ៧២, ៩០, ៩១។ សេចក្ដីប្រកាសព័ត៌មានពីសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

លើសំណុំរឿង ០០៤/០២ អនុលោមតាមមូលដ្ឋានដែលច្បាប់ពុំអនុញ្ញាត”។

មេធាវីការពារក្តីសូមដាក់លិខិតនេះជាភាសាអង់គ្លេសជាមុនសិន ហើយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយឲ្យបានឆាប់រហ័សបំផុត។ លិខិតនេះបានដាក់ជូនទៅអង្គភាពបកប្រែភាសានៅថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០២០។

**ក. *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* មិនអាចទទួលយកបាន យោងតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង**

បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ មិនអាចទទួលយកបាន ដោយសារវាពុំមែនជាបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែល “មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី’ យោងតាមលក្ខខណ្ឌតម្រូវតាមវិធាន ១០៤(ក)(ក) នៃវិធានផ្ទៃក្នុង។ យ៉ាងច្រើនបំផុត វាគ្រាន់តែជាបណ្តឹងសាទុក្ខប្រឆាំងនឹង ‘សេចក្តីថ្លែងការណ៍ របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន” (“*សេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា*”) ដែលចៅក្រមអង្គជំនុំជម្រះសាលាដំបូង ខ្លួនឯងបានគូសបញ្ជាក់ថា វាពុំមែនជាសេចក្តីសម្រេច ហើយពុំមានអានុភាពតាមផ្លូវច្បាប់[3]។ ម៉្យាងវិញទៀត វាគ្រាន់ជាការប៉ុនប៉ងប្តឹងសាទុក្ខសាជាថ្មីចំពោះលទ្ធផលនៃ*សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* (“*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*”) ដែលក្របខ័ណ្ឌគតិយុត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានចែង ឬក៏អនុញ្ញាតឲ្យធ្វើដូច្នេះឡើយ[4]។

---

[3] អង្គជំនុំជម្រះសាលាដំបូង ‘សេចក្តីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន’ (‘*សេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា*’) អាចរកមើលបាននៅលើគេហទំព័រ https://eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao (‘ដោយសារតែការចេញសេចក្តីសម្រេចជាផ្លូវការមួយរបស់អង្គជំនុំជម្រះសាលាដំបូង មិនអាចធ្វើទៅបាននោះ ចៅក្រមអន្តរជាតិបានយល់ព្រមចូលរួមជាមួយសហសេវិកចៅក្រមជាតិរបស់ខ្លួនក្នុងការចេញនូវសេចក្តីថ្លែងការណ៍រួមមួយនេះ។ បើទោះបីជាសេចក្តីថ្លែងការណ៍រួមនេះពុំមានអានុភាពផ្លូវច្បាប់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងសង្ឃឹមថា វានឹងជួយផ្តល់នូវតម្លាភាពនិងភាពច្បាស់លាស់ដល់សាធារណជននិងភាគីពាក់ព័ន្ធនៃសំណុំរឿងនេះ’)។

[4] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ អ.វ.ត.ក”) មាត្រា២៣ថ្មី (ដោយលើកឡើងថា អង្គបុរេជំនុំជម្រះពិនិត្យមើលឡើងវិញលើសេចក្តីសម្រេច និងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ហើយសាលដីការបស់អង្គបុរេជំនុំជម្រះ (ឬ សេចក្តីពិចារណា) បិទផ្លូវប្តឹងតវ៉ា) មាត្រា ៣៦*ថ្មី* (អង្គជំនុំជម្រះតុលាការកំពូល ‘ត្រូវសម្រេចលើបណ្តឹងសាទុក្ខដែលបានប្តឹងដោយជនជាប់ចោទ ជនរងគ្រោះ ឬ សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង’)។

អនុលោមតាមវិធានផ្ទៃក្នុង ភាគីអាចប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ យោងតាមវិធាន ១០៤(៤)(ក) "*សេចក្ដីសម្រេច* ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" បើកផ្លូវឲ្យប្ដឹងសាទុក្ខភ្លាមៗ[5]។ ស្រដៀងគ្នានេះដែរ វិធាន ១០៤(១) ចែងអំពីបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខប្រឆាំងនឹង*សេចក្ដីសម្រេច*។ ដូច សហព្រះរាជអាជ្ញាអន្តរជាតិបានគូសបញ្ជាក់នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា អនុស្សរណៈអាចត្រូវបានចាត់ទុកជាសេចក្ដីសម្រេចប្រសិនបើ "មាន*ការបញ្ជាក់*ពីចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត' ដោយមិនពិចារណាលើទម្រង់របស់វា[6]។ ទោះបីជា សហព្រះរាជអាជ្ញាអន្តរជាតិបានដកស្រង់ត្រឹមត្រូវនូវសេចក្ដីសន្និដ្ឋានចុងក្រោយរបស់អង្គជំនុំជម្រះតុលាការកំពូលក៏ដោយ គាត់បានលុបចោលសំអាងហេតុត្រង់ទិដ្ឋភាពសំខាន់ ជាពិសេស *ការបញ្ជាក់*ពាក់ព័ន្ធពីចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត[7]។ យោងតាមយុត្តិ

---

[5] វិធានផ្ទៃក្នុងស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់ព្រហ្មទណ្ឌកម្ពុជា។ *សូមមើល ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៨៥* ('កាលណាតុលាការចេញសាលក្រមចាត់របៀប បណ្ដឹងឧទ្ធរណ៍អាចត្រូវទទួលបានភ្លាម ប្រសិនបើសាលក្រមនេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្ដី')។ មាត្រា ៤២១ ('កាលណាតុលាការចេញសាលដីកាចាត់របៀប បណ្ដឹងសាទុក្ខអាចត្រូវទទួលបានភ្លាម ប្រសិនបើសាលដីកានេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលដីកាចាត់របៀបនឹងអាចត្រូវដាក់ជូនតុលាការកំពូលពិនិត្យជាមួយគ្នានឹងសាលដីកាលើអង្គសេចក្ដីតែប៉ុណ្ណោះ')។

[6] *បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤២*(ដកស្រង់សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-អជសដ/អជសដ *សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១* ឯកសារ **E163/5/1/13** ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ៣០។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-អជសដ/អជសដ *សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង* ('*សេចក្ដីសម្រេចអនុលោមតាមវិធាន ៣៥*') ឯកសារ **E176/2/1/4** ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ២៥)។

[7] *សេចក្ដីសម្រេចអនុលោមតាមវិធាន ៣៥* កថាខណ្ឌ ២៥ (ការគូសបញ្ជាក់បន្ថែម)។ ឧទាហរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិគ្រាន់តែយោងផ្នែកខ្លះនៃចំណុចដកស្រង់ដូចខាងក្រោម៖ 'សេចក្ដីសម្រេចរបស់តុលាការត្រូវតែបង្ហាញ *ការបញ្ជាក់ណាមួយ* អំពីចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត។ ត្រង់ចំណុចនេះ ជាការចាំបាច់ដែលសេចក្ដីសម្រេចមួយតាមផ្លូវតុលាការ *ត្រូវចាត់ការលើបញ្ហាអង្គច្បាប់មួយ ដែលស្ថិតនៅចំពោះមុខខ្លួនឲ្យបានច្បាស់លាស់*។ ហេតុដូច្នេះ សេចក្ដីសម្រេចតាមផ្លូវតុលាការ *គួរតែប្បីមានផ្នែកមួយដែលមានអានុភាព ("ខ សម្រាប់អនុម័តច្បាប់" ឬ "ផ្នែកសម្រេចសេចក្ដី") ដែលដោះស្រាយចំពោះអង្គសេចក្ដី ហើយ/ឬ បញ្ហានីតិវិធី* ដោយបង្កើត កែប្រែ បដិសេធចោល ឬ ទទួលយកនូវទំនាក់ទំនងដែលសំអាងលើច្បាប់ ដែលមានជាប់ពាក់ព័ន្ធទៅនឹងភាគីនានា។ លើសពីនេះទៀត ជាទម្លាប់ដ៏ខ្ជាប់ខ្ជួនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលសេចក្ដីសម្រេចដែលបើកផ្លូវប្ដឹងសាទុក្ខ ដោយអនុលោមតាមវិធានផ្ទៃក្នុង ត្រូវចេញជាលាយលក្ខណ៍អក្សរ។ ការអនុវត្តន៍នេះ ទោះបីជាមិនបានតម្រូវដោយច្បាប់ក៏ដោយ ក៏បានផ្ដល់នូវភាពច្បាស់លាស់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធីដូចដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ហើយនិងអាចផ្ដល់ឲ្យមានដំណើរការពិនិត្យមើលឡើងវិញប្រកបដោយប្រសិទ្ធភាព។ ជាងនេះទៀត ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងក្នុងឱកាសខុសៗគ្នាថា *រាល់សេចក្ដីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថា ជាសេចក្ដីសម្រេចផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែ*

សាស្ត្រនៃសំណុំរឿង ០០២ សេចក្តីសម្រេច ឬ ចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាតគឺកំណត់ដោយកត្តាដូចតទៅ៖ (1) វា "ត្រូវចាត់ការលើបញ្ហាអង្គច្បាប់មួយ ដែលស្ថិតនៅចំពោះមុខខ្លួនឱ្យបានច្បាស់លាស់" (2) មាន "ផ្នែកមួយដែលមានអានុភាព (" ខ សម្រាប់អនុម័តច្បាប់" ឬ "ផ្នែកសម្រេចសេចក្តី") ដែលដោះស្រាយចំពោះអង្គសេចក្តី ហើយ/ឬ បញ្ហានីតិវិធីដែរ ដោយបង្កើត កែប្រែ បដិសេធចោល ឬ ទទួលយកនូវទំនាក់ទំនងដែលសំអាងលើច្បាប់ ដែលមានជាប់ពាក់ព័ន្ធទៅនឹងភាគីនានាឮ"; (3) វាត្រូវចេញជាលាយលក្ខណ៍អក្សរ ដើម្បីធានាតម្លាភាព សច្ចភាពផ្លូវច្បាប់ និង "ដំណើរការពិនិត្យមើលឡើងវិញប្រកបដោយប្រសិទ្ធភាព" និង (4) ថាតើវាផ្តល់ "សំអាងហេតុគ្រប់គ្រាន់ចំពោះសេចក្តីសម្រេចទាំងនោះ ដែលជាផលនៃការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌"[8]។

នៅពេលយកកត្តាទាំងនេះទៅអនុវត្តនៅក្នុងរឿងក្តី អោ អាន សេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា ពុំមែនជា "ចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត" ទេ ដូច្នេះ វាពុំត្រូវបានចាត់ទុកជាសេចក្តីសម្រេចនោះឡើយ។ ទោះសេចក្តីថ្លែងការណ៍នេះធ្វើឡើងជាលាយលក្ខណ៍អក្សរក៏ដោយ វាពុំបាន "ត្រូវចាត់ការលើបញ្ហាអង្គច្បាប់មួយ ដែលស្ថិតនៅចំពោះមុខខ្លួនឱ្យបានច្បាស់លាស់' ពុំមាន "ផ្នែកមួយដែលមានអានុភាព" សម្រេចលើចំណុចសារធាតុផ្លូវច្បាប់ ឬ នីតិវិធី ឬ ពុំបានផ្តល់សំអាងហេតុពេញលេញសម្រាប់គាំទ្រលើសេចក្តីសន្និដ្ឋាននោះឡើយ[9]។ ផ្ទុយមកវិញ ដូចអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ សេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា គឺគ្រាន់តែជាសេចក្តីថ្លែងការណ៍រួមរបស់ចៅក្រម ដើម្បីផ្តល់ "តម្លាភាព និងភាពច្បាស់លាស់" សម្រាប់សាធារណជន និងភាគីតែប៉ុណ្ណោះ ដោយសារសេចក្តីសម្រេចផ្លូវការពុំអាចធ្វើទៅបាន[10]។

លើសពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិសំអាងលើសកម្មភាពនៅស្ងៀមមិនចាត់ការរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០៤/២ ដូចជា ការខកខានមិនបានផ្តល់សិទ្ធិអនុញ្ញាតឱ្យដាក់ឯកសារ និងសេចក្តីជូនដំណឹងតាមទម្រង់អេឡិចត្រូនិក ឬ ការប្រគល់ត្រឡប់ឯកសារក្រដាសដែលភាគីបានដាក់ ដើម្បីអះអាងថាបណ្តឹងសាទុក្ខរបស់គាត់អាចទទួលយកបាន[11]។ ទោះបីជាយ៉ាងនេះក្តី ទឡ្ហីករណ៍នេះមានចន្លោះប្រហោងដូចគ្នា។ ដូចបានពន្យល់នៅក្នុងផ្នែក គ ខាងក្រោម ទឡ្ហីករណ៍នេះបានសំអាងលើការសន្មតមិនត្រឹមត្រូវរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងតាមផ្លូវច្បាប់តាំងពីដំបូង ដូច្នេះ មាន

---

*ប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ ចំពោះសេចក្តីសម្រេចទាំងនោះ* ដែលជាផលនៃការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌'។

[8] *សេចក្តីសម្រេចអនុលោមតាមវិធាន ៣៥* កថាខណ្ឌ ២៥។

[9] *សេចក្តីសម្រេចអនុលោមតាមវិធាន ៣៥* កថាខណ្ឌ ២៥។

[10] *សេចក្តីថ្លែងការណ៍ចុះថ្ងៃទី ០៣ ខែមេសា*។

[11] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៤២-៤៤។

កាតព្វកិច្ចបំពេញកិច្ចបន្ត។ គាត់បានមើលរំលងករណីដែលថា សំណុំរឿង ០០៤/២ ត្រូវបានរំលត់ជាស្ថាពរ ក្រោយពេលអង្គបុរេជំនុំជម្រះចេញ*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[12]។ ក្រោយកាលបរិច្ឆេទនេះ ពុំឃើញមានកិច្ចដំណើរការនីតិវិធីផ្សេងទៀតនៅក្នុងសំណុំរឿង ០០៤/២ នោះទេ ហើយ អង្គជំនុំជម្រះសាលាដំបូង ក៏ត្រូវបានតម្រូវឱ្យបំពេញកិច្ចអ្វីដែរ។ កិច្ចដែលនៅសេសសល់តែមួយគត់សម្រាប់ សហចៅក្រមស៊ើបអង្កេតទាំងពីរគឺការបោះត្រាតម្កល់សំណុំរឿងនៅបណ្ណសារដ្ឋាន អនុលោមតាមវិធាន ៦៩(២) តាមសំណើសុំរបស់មេធាវីការពារក្តីកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០[13]។ អាស្រ័យហេតុនេះ សកម្មភាពនៅ ស្ងៀមពុំបំពេញកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដូចបានចោទប្រកាន់ និងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា ពុំមែនជាសេចក្តីសម្រេចដែលអាចបើកផ្លូវឱ្យប្តឹងសាទុក្ខនោះឡើយ។ ដូច្នេះ *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* មិនអាចទទួលយកបាននៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ១០៤(៤)(ក)។

**ខ. *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* មិនអាចទទួលយកបាន យោងតាមយុត្តាធិការដែលអង្គជំនុំជម្រះតុលាការកំពូល មានជាប់មកជាមួយ**

សហព្រះរាជអាជ្ញាអន្តរជាតិផ្តល់ទឡ្ហីករណ៍មិនត្រឹមត្រូវថា បណ្តឹងសាទុក្ខរបស់គាត់អាចទទួលយកបាន យោងតាមយុត្តាធិការ ដែលអង្គជំនុំជម្រះតុលាការកំពូលមានជាប់មកជាមួយ ដើម្បីធានា "ការធានានូវកិច្ចការរដ្ឋបាលតុលាការឱបានល្អ" "ដើម្បីធានានូវការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌" "ដើម្បីបំពេញបេសកកម្មរបស់តុលាការឱ្យបានត្រឹមត្រូវ" និង "រក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងការពារផលប្រយោជន៍យុត្តិធម៌"[14]។

ដើម្បីជាមូលដ្ឋានគាំទ្រការអះអាងរបស់គាត់សហព្រះរាជអាជ្ញាអន្តរជាតិ ដំបូង យោងលើយុត្តិសាស្ត្រពីសាលាក្តីអន្តរជាតិផ្សេងទៀត ប៉ុន្តែ គាត់ពុំបានអនុវត្តយុត្តិសាស្ត្រនេះឱ្យបានសមស្របនោះទេ[15]។ មេធាវីការពារក្តីសន្និដ្ឋានថា បើទោះជាគាត់បានអនុវត្តបានត្រឹមត្រូវក៏ដោយ ក៏កាលៈទេសៈនៃយុត្តិសាស្ត្រដែលមានជាប់មកជាមួយដូចបានកំណត់ដោយសាលាក្តីអន្តរជាតិផ្សេងទៀត មិនអាចយកមកអនុវត្តនៅក្នុងរឿងក្តីរបស់ អោ អាន នោះឡើយ។ ចំណុចទី១ ពុំមាននៅសេសសល់នូវ "ការរាំងស្ទះផ្នែកច្បាប់ ឬឧបសគ្គផ្នែកអនុវត្ត" ឬ "ចន្លោះ

---

[12] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៦០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ('*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*') ឯកសារ **D359/24 & D360/33** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[13] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ('*សំណើសុំដាក់បញ្ចូលទៅក្នុងបណ្ណសារ*) ឯកសារ **D363** ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[14] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៤៦, ៤៨។

[15] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៤៧។

ប្រហោងដែលអាចមាននៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់” ដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយ[16]។ ដូចបានពន្យល់ខាងលើអង្គបុរេជំនុំជម្រះបានរំលត់ជាស្ថាពរនូវកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៩ ក្រោយពេលអង្គបុរេជំនុំជម្រះចេញ*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*។ កិច្ចដែលនៅសេសសល់តែមួយគត់ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខគឺសហចៅក្រមស៊ើបអង្កេតទាំងពីរគឺការបោះត្រាតម្កល់សំណុំរឿងនៅបណ្ណសារដ្ឋាន។ មេធាវីការពារក្តីបានដាក់ *សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* (“*សំណើសុំដាក់បញ្ចូល ទៅក្នុងបណ្ណសារ*”) នៅក្នុងខែមីនា ឆ្នាំ២០២០[17]។ ចំណុចទី២ ទាំង អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានធានាថា “យុត្តិធម៌មិនត្រឹមតែធ្វើបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានគេ*មើលឃើញ* ថានឹងធ្វើបានផងដែរ”[18]។ អង្គបុរេជំនុំជម្រះបានដាក់អនុស្សរណៈផ្ទៃក្នុង ដោយបានពន្យល់អំពីកត្តារាំងស្ទះនៅក្នុងសំណុំរឿង កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០[19] ហើយ ជាពិសេស អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា ដើម្បីផ្តល់តម្លាភាព និងភាពច្បាស់លាស់។

ផ្ទុយមកវិញ ទឡ្ហីករណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ដូចបានគូសបញ្ជាក់អំពីយុត្តាធិការដែលមានជាប់មកជាមួយគឺគ្រាន់ជាការបង្កប់ន័យថា កត្តារាំងស្ទះបច្ចុប្បន្នគឺផ្អែកលើមូលដ្ឋាននៃនត្តិភាពឯករាជ្យ និងអនាគតិតុលាការរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង ដោយសារការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងសំណុំរឿង ០០៤/២[20]។ ការបង្កប់ន័យនេះ ដែលលើកឡើងជាក់លាក់អំពី “សីលធម៌” និង “សុចរិតភាព” – ត្រូវបានលើកឡើងដដែលច្រើនលើកច្រើនសានៅក្នុង*បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ព្រមទាំង សេចក្តីប្រកាសព័ត៌មាននាពេលថ្មីៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[21]។ ពុំមានការបកស្រាយសមហេតុសមផលផ្សេងពីនេះលើទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ អាចធ្វើទៅបាននោះទេ។ ក៏ប៉ុន្តែ ទោះបីជាការបង្កប់ន័យនេះមានស្ថានទម្ងន់ក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិពុំបានផ្តល់ភ័ស្តុតាងអ្វីឡើយ។ ការចោទប្រកាន់ដែលគ្មានភ័ស្តុតាងគាំទ្រពុំអាចជាមូលដ្ឋានគាំទ្រអំពីការអនុវត្តយុត្តាធិការដែលអង្គជំនុំជម្រះ

---

[16] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៧។

[17] *សំណើសុំដាក់បញ្ចូលទៅក្នុងបណ្ណសារ*។

[18] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៧។

[19] អនុស្សរណៈអន្តរការិយាល័យ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងការបញ្ជូនសំណុំរឿង ០០៤/២ (“អនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០”) ដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានផ្ញើជូនទៅភាគី។

[20] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៦។ ឧទាហរណ៍ នៅក្នុងលេខយោងជើងទំព័រ សហព្រះរាជអាជ្ញាអន្តរជាតិបង្កប់ន័យថា អង្គជំនុំជម្រះតុលាការកំពូល ត្រូវអនុវត្តយុត្តាធិការដែលមានជាប់មកជាមួយដោយសារថាមានការចោទប្រកាន់អំពីការជ្រៀតជ្រែកចូលនៅក្នុងដំណើរការស្វែងរកយុត្តិធម៌នៅក្នុងសំណុំរឿង ០០៤/២។

[21] សេចក្តីប្រកាសព័ត៌មានពីសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

តុលាការកំពូល មានជាប់មកជាមួយនោះឡើយ។ ដូច្នេះ ពុំមានមូលដ្ឋានអ្វីដែលអង្គជំនុំជម្រះតុលាការកំពូល អាចយកមកសំអាងដើម្បីទទួលយក *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* នោះឡើយ។

**គ. អង្គជំនុំជម្រះសាលាដំបូងមិនបាន "រំលត់ជាធរមាននៃសំណុំរឿង ០០៤/២ តាមរយៈបរាជ័យរបស់ខ្លួន ក្នុងដំណើរការធ្វើឱ្យរឿងក្តីទៅជំនុំជម្រះ" ហេតុនេះ មិនបានប្រព្រឹត្តកំហុសអង្គច្បាប់ទេ**

បើតាម សហព្រះរាជអាជ្ញាអន្តរជាតិ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងមិនបាន "ដំណើរការធ្វើឱ្យរឿងក្តីទៅជំនុំជម្រះ" ចាប់តាំងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដោយសារមូលហេតុនៃការខ្វែងយោបល់គ្នារវាងចៅក្រមជាតិនិងអន្តរជាតិ គឺជាការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ហេតុនេះវាជាកំហុសអង្គច្បាប់។ ជំហរនេះមិនត្រឹមត្រូវទេ ដោយសារមានសំអាងហេតុនានាដូចខាងក្រោម៖

ទីមួយ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សំអាងទៅលើការសន្មតថា អង្គជំនុំជម្រះសាលាដំបូង បានទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យដោយមានប្រសិទ្ធភាព ហើយថា អង្គជំនុំជម្រះមានសិទ្ធិអំណាចតាមផ្លូវច្បាប់ ក្នុងដំណើរការធ្វើឱ្យរឿងក្តីទៅជំនុំជម្រះ ឬរំលត់រឿងក្តីនេះ។ សហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញការសន្មតនេះថាជាសច្ចភាពផ្លូវច្បាប់ ទោះបីអាចមានការបកស្រាយតែមួយគត់ចំពោះភាពចន្លោះប្រហោងដែលមិនធ្លាប់មាន និងមិនអាចគ្រប់គ្រងបាន ដែលកើតឡើងដោយសារការចេញដីកាដំណោះស្រាយពីរដាក់ដោយឡែកពីគ្នា និងផ្ទុយគ្នាក៏ដោយ។ ទោះបីមានការអះអាងនានារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អំពីជំហរជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ លើបញ្ហានេះក៏ដោយ[22] តែការពិត អង្គបុរេជំនុំជម្រះ មិនអាចទទួលបានសំឡេងភាគច្រើនលើសលុបដើម្បីចេញសេចក្តីសម្រេចដែលមានអានុភាព និងផលវិបាកគតិយុត្តិនៃសេចក្តីសម្រេចដែលខ្វែងយោបល់គ្នានេះបានឡើយ[23]។ តាមពិត ចៅក្រមភាគច្រើននៅ អង្គបុរេជំនុំជម្រះ បានសម្រេចថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ តម្រូវឱ្យលើកលែងចោទប្រកាន់នៃសំណុំរឿង ០០៤/២ នៅក្នុងកាលៈទេសៈទាំងនេះ[24]។

ជាងនេះទៀត អនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុងចែងថា ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គជំនុំជម្រះត្រូវតម្កល់ទុកជាបានការ។ ហេតុនេះ *ដីកាសម្រេចលើកលែងចោទប្រកាន់ អោន អាន ("ដីកាសម្រេចលើកលែងចោទប្រកាន់")* បន្តនៅមានសុពលភាព មិនប៉ះពាល់

---

22 *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥១។

23 *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤, ១៧០-៣០២, ៣០៤-៣២៩។

24 *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* កថាខណ្ឌ ២៩៥-៣០២។

ដោយបណ្ដឹងឧទ្ធរណ៍នោះឡើយ[25]។ ការណ៍ដែលថា *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[26] ក៏អាចតម្កល់ទុកជាបានការដែរ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង មិនមានឥទ្ធិពលទៅលើសុពលភាពរបស់ *ដីកាសម្រេចលើកលែងចោទប្រកាន់* ឡើយ (ជាពិសេសបើផ្អែកលើគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងការគាំទ្ររបស់ចៅក្រមភាគច្រើននៃអង្គបុរេជំនុំជម្រះ ដល់ការលើកលែងចោទប្រកាន់នៃសំណុំរឿងនេះ)[27]។

ថ្វីត្បិតតែមានការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិផ្ទុយពីនេះក៏ដោយ តែវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ឬបទប្បញ្ញត្តិណាផ្សេងទៀតចំពោះបញ្ហានោះមិនបង្កើតជាឋានានុក្រមនៃភាពអាជ្ញាបញ្ញា រវាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ[28]។ ហេតុនេះ មេធាវីការពារក្ដីយល់ស្របជាមួយចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ (មតិភាគច្រើន) ចៅក្រមជាតិនៃ អង្គជំនុំជម្រះសាលាដំបូង (មតិភាគច្រើន) និងសហព្រះរាជអាជ្ញាជាតិដែលថា អង្គជំនុំជម្រះសាលាដំបូង មិនបានទទួលយកសំណុំរឿង ០០៤/២ មក

---

[25] សំណុំរឿងលេខ ០០៤/២/០៧-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ("ដីកាសម្រេចលើកលែងចោទប្រកាន់")* ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[26] សំណុំរឿងលេខ ០០៤/២/០៧-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ **D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[27] មេធាវីការពារក្ដីបានបង្ហាញទឡ្ហីករណ៍នេះស្របគ្នានៅក្នុងឯកសារនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះ៖ ក្រុមមេធាវីការពារក្ដី អោ អាន *"សំណើការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលយកសំណុំរឿង ០០៤/២ តាមផ្លូវច្បាប់ទេ ឬជាជម្រើសម្យ៉ាងទៀត សំណើការពន្យារពេល និងការណែនាំសម្រាប់ការដាក់អញ្ញត្តកម្ម អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។ សំណុំរឿងលេខ ០០៤/២/០៧-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *សំណើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ* ឯកសារ **D359/27 & D360/36** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។ សំណុំរឿងលេខ ០០៤/២/០៧-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ* ឯកសារ D359/31 & D360/40 ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។ *សំណើសុំដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ*។

[28] នៅក្នុងកថាខណ្ឌ ៥២ សហព្រះរាជអាជ្ញាអន្តរជាតិលើកជាទឡ្ហីករណ៍ថា "ប្រសិនបើអ្នកធ្វើសេចក្ដីព្រាងមានបំណងដោះស្រាយជាក់លាក់លើផលប៉ះពាល់នៃបរាជ័យរបស់អង្គបុរេជំនុំជម្រះ ក្នុងការបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់នោះ ពួកគេច្បាស់ជាបានធ្វើដូច្នោះនៅក្នុងវិធាន ៧៧(១៣)(ក) ហើយ ប៉ុន្តែបានជ្រើសរើសមិនធ្វើដូច្នោះទេ"។ *បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥២។ ទឡ្ហីករណ៍នេះមិនយកចិត្តទុកដាក់ដល់ការណ៍ដែលថា អ្នកធ្វើសេចក្ដីព្រាងមិនបានប្រមើលមើលពីការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នានោះទេ។ ក្នុងកាលៈទេសៈណាក៏ដោយ ពាក្យពេចន៍នៅក្នុងវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ចែងយ៉ាងពេញលេញនូវលទ្ធភាពនៃការបញ្ជាក់ដល់ដីកាសម្រេចលើកលែងចោទប្រកាន់ ឬមិនត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលុប ទៅលើបណ្ដឹងឧទ្ធរណ៍នោះទេ។

ពិនិត្យតាមផ្លូវច្បាប់ទេ[29]។ ការណ៍ដែលថា អង្គជំនុំជម្រះសាលាដំបូង មិនអាចទទួលបានមូលដ្ឋានរួមទៅលើបញ្ហាមួយដែលមានការខ្វែងយោបល់នៅ អង្គបុរេជំនុំជម្រះ និង នៅការិយាល័យសហព្រះរាជអាជ្ញា មិនអាចសន្និដ្ឋានចាត់ទុកថាជា "កំហុសអង្គច្បាប់" បានឡើយ។ សរុបមក "គោលជំហរជាក់ស្តែង" នៅដំណាក់កាលជំនុំជម្រះគឺថា ការមិនទទួលបានសំឡេងគាំទ្រលើសលុបរបស់ចៅក្រមដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះ បណ្តាលឲ្យរំលត់កិច្ចដំណើរការនីតិវិធី តាមរយៈការលើកលែងបទចោទ[30]។

ជាងនេះទៀត ទោះក្នុងកម្រិតណាក៏ដោយ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូង មិន "ដំណើរការសំណុំរឿងទៅជំនុំជម្រះ" មិនអាចរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ បានឡើយ។ សំណុំរឿងនេះត្រូវបានរំលត់ជាធរមានដោយ អង្គបុរេជំនុំជម្រះ ហើយ ជាសេចក្តីសម្រេចដែលបិទផ្លូវតវ៉ា។

ជាងនេះទៀត មានការបង្ហាញថា *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ* លុបបំបាត់ចោលនូវ *សំណើសុំដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ* របស់ អោ អាន[31]។ ដូចបានលើកឡើងនៅក្នុងការអះអាងរបស់ អោ អាន គឺថា អនុលោមតាមវិធាន ៦៩(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ជាអ្នកសម្រេចថាតើត្រូវបញ្ចូលសំណុំរឿងដែលត្រូវបានលើកលែងចោទប្រកាន់ទៅក្នុងបណ្ណសារ ឬត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពទៅអង្គជំនុំជម្រះសាលាដំបូង[32]។ សកម្មភាពរង់ចាំការសម្រេចពី សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៦៩(២) កិច្ចនានារបស់ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០៤/២ មិនខុសច្បាប់ទេ ហើយក៏មិនអាចជា "ការរំលត់ជាធរមាននៃរឿងក្តី" ដែរ។

### ឃ. អង្គជំនុំជម្រះសាលាដំបូងពុំមានបញ្ហាដែលត្រូវធ្វើការវិនិច្ឆ័យនៅចំពោះមុខខ្លួន ដែលតម្រូវឲ្យអនុវត្តយុត្តា

---

[29] សេចក្តីប្រកាសព័ត៌មានពីសហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងជនត្រូវចោទ អោ អាន ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។ ([...] អង្គជំនុំជម្រះសាលាដំបូងពុំមានសិទ្ធិអំណាចណាមួយក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងសំណុំរឿងនេះឡើយ ហើយក៏មិនមានការជំនុំជម្រះជនត្រូវចោទ អោ អាន នេះដែរ នៅពេលបច្ចុប្បន្ន និងនាពេលអនាគត [...])។

[30] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា") មាត្រា ៤(១)(ក)។ ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ១៤(១)(១)(ក)។ វិធាន ៩៨(៤) នៃវិធានផ្ទៃក្នុង។

[31] *សំណើសុំដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ*។

[32] អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង "ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ"។ ទោះបីវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុងអនុវត្តដោយផ្ទាល់ដល់ស្ថានភាពដែលគ្មានបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ក្តី តែពុំមានបទប្បញ្ញត្តិស្មើគ្នាចែងសម្រាប់ស្ថានភាពដែលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានបញ្ជាក់ ឬមិនត្រូវបានច្រានចោលដោយបណ្តឹងឧទ្ធរណ៍ឡើយ (គឺថា សំឡេងភាគច្រើនលើសលុបរបស់អង្គបុរេជំនុំជម្រះ ឬដោយសារ អង្គបុរេជំនុំជម្រះមិនទទួលបានសំឡេងភាគច្រើនលើសលុប)។ ភាពប្រត្យក្សបង្ហាញថា នៅក្នុងកាលៈទេសៈទាំងនេះ សំណុំរឿងត្រូវបញ្ចូលទៅក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង។

ធិការផ្ទាល់របស់ខ្លួនទេ ហេតុនេះពុំបានប្រព្រឹត្តកំហុសអង្គច្បាប់ ឬបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ

បើតាមសហព្រះរាជអាជ្ញាអន្តរជាតិ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានចេញសេចក្តីសម្រេចទៅលើសំណើនានារបស់ខ្លួន ជា "ការបដិសេធក្នុងការអនុវត្តយុត្តាធិការផ្ទាល់របស់ខ្លួនដើម្បីសម្រេចលើបញ្ហានានាដែលត្រូវដោះស្រាយតាមច្បាប់នៅចំពោះមុខខ្លួន" ហើយបង្កជាកំហុសអង្គច្បាប់ ឬការបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន[33]។ ទឡ្ហីករណ៍នេះពុំមានមូលដ្ឋានទេ ដោយសារមានសំអាងហេតុនានាដូចខាងក្រោម៖

ទីមួយ អនុលោមតាមសំអាងហេតុនានាដែលបានលើកឡើងនៅក្នុងផ្នែក គ ខាងលើ អង្គជំនុំជម្រះសាលាដំបូង មិនបានទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យតាមផ្លូវច្បាប់ទេ ហេតុនេះពុំមានបញ្ហានានាដែលត្រូវដោះស្រាយតាមច្បាប់នៅចំពោះមុខខ្លួនឡើយ។

ទីពីរ ទោះបីគ្រាន់តែយកមកធ្វើជាទឡ្ហីករណ៍ដែលថា អង្គជំនុំជម្រះសាលាដំបូងពិតជាមានបញ្ហាដែលត្រូវធ្វើការវិនិច្ឆ័យនៅចំពោះមុខខ្លួន (ជំហរដែលជំទាស់ដោយមេធាវីការពារក្តី) ទៅតាមការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក៏ដោយ ក៏យុត្តាធិការពីធម្មជាតិរបស់អង្គជំនុំជម្រះក្នុងការសម្រេចទៅលើបញ្ហាទាំងនេះកើតចេញពី "អំណាចរបស់អង្គជំនុំជម្រះដើម្បីធ្វើអ្វីដែលចាំបាច់ដើម្បីរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងការគោរពដល់យុត្តិធម៌ [និង] កាតព្វកិច្ចតាមក្រមសីលធម៌របស់ចៅក្រម"[34]។ ការលើកយោងជាច្រើនរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះឯករាជភាព និងភាពមិនលម្អៀងរបស់តុលាការ[35] និង "អំណាចក្នុងការដោះស្រាយចំពោះការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ"[36] បង្ហាញច្បាស់ថា ភាពខ្វះចន្លោះនាពេលបច្ចុប្បន្នកើតឡើងដោយសារកង្វះឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ ដោយសារមានការជ្រៀតជ្រែកផ្នែកនយោបាយទៅក្នុងសំណុំរឿងនេះ។ ការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរទាំងនេះធ្វើឡើងដោយគ្មានភស្តុតាងគាំទ្រទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបង្ហាញភស្តុតាងដែលគាត់បានសំអាង ដើម្បីធ្វើការចោទប្រកាន់ទាំងនេះ ឬជាជម្រើសម្យ៉ាងទៀត គាត់ត្រូវដកការចោទប្រកាន់របស់ខ្លួនវិញ។

ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងបន្ថែមថា "ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តច្បាប់ និង/ឬ អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងត្រឹមត្រូវនោះ សំណុំរឿង ០០៤/២ នឹងត្រូវបានដំណើរការទៅជំនុំជម្រះទៅហើយ" ហើយថា ការដែលអង្គជំនុំជម្រះមិនបានធ្វើបែបនេះ "ធ្វើឱ្យខូចប្រយោជន៍របស់ភាគីក្នុងសំណុំរឿង ០០៤/២ [និង] មានលក្ខណៈមិនសមហេតុផល និងមិនយុត្តិធម៌ទាល់តែសោះ ដែលវាមានតម្លៃស្មើ

[33] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៩។

[34] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៩។

[35] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៤៨ និង ជើងទំព័រ ៦៩, ៧២, ៩១។

[36] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ជើងទំព័រ ៩០។

ទៅនឹងការរំលោភឆន្ទានុសិទ្ធិ”[37]។ ផ្ទុយទៅវិញ ទោះបី អង្គជំនុំជម្រះសាលាដំបូង ពិតជាយុត្តាធិការផ្ទាល់ក្នុងការសម្រេចទៅលើសំណើនានារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ក្តី (ដែលអង្គជំនុំជម្រះពុំមានទេ) វាពុំមែនជាការពិតទេដែលថា ចំណុចនេះនឹងនាំឲ្យសំណុំរឿង ០០៤/២ ត្រូវបានដំណើរការទៅជំនុំជម្រះនោះ។ អនុលោមតាមសំអាងហេតុនានាដែលបានលើកឡើងនៅក្នុងផ្នែក គ ខាងលើ នីត្យានុកូលភាពនៃការជំនុំជម្រះ ដោយសារមាន *ដីកាសម្រេចលើកលែងចោទប្រកាន់* ដែលមានសុពលភាព ត្រូវបានជំទាស់ដោយចៅក្រមភាគច្រើននៅអង្គបុរេ និងជារំលោភដល់មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ នៅក្នុងកាលៈទេសៈទាំងនេះ ការដែល អង្គជំនុំជម្រះសាលាដំបូង មិនអនុវត្តតាមយុត្តាធិការផ្ទាល់ (ដែលត្រូវបានអះអាង) របស់ខ្លួន មិនអាចចាត់ទុកថា “មានលក្ខណៈមិនសមហេតុផល និងមិនយុត្តិធម៌ទាល់តែសោះ ដែលវាមានតម្លៃស្មើទៅនឹងការរំលោភឆន្ទានុសិទ្ធិ” បានឡើយ។

**ង. អង្គជំនុំជម្រះសាលាដំបូងមិនបានប្រព្រឹត្តកំហុសអង្គច្បាប់ ឬបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបន្ថែមវិធានការរដ្ឋបាលនៅក្នុងសំណុំរឿង ០០៤/២ ដែលមិនតម្រូវពីមុន នោះឡើយ**

អង្គជំនុំជម្រះសាលាដំបូង មិនបានខកខានក្នុងការ “អនុវត្តតាមច្បាប់នីតិវិធីត្រឹមត្រូវ” ឬ បង្កើតតាមអំពើចិត្តនូវ “វិធានការរដ្ឋបាលដែលមិនតម្រូវពីមុន” នោះឡើយ ហេតុនេះអង្គជំនុំជម្រះពុំបានប្រព្រឹត្តកំហុសអង្គច្បាប់ ឬបំពានឆន្ទានុសិទ្ធិរបស់ខ្លួនទេ[38]។ សហព្រះរាជអាជ្ញាអន្តរជាតិ សំអាងតែទៅលើការឯកសារតែមួយគត់ដើម្បីអះអាងថា អង្គជំនុំជម្រះសាលាដំបូង បានទទួលយកសំណុំរឿង ០០២ អនុលោមទៅតាម “សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដោយ អៀង សារី, អៀង ធីរិទ្ធិ, នួន ជា និង ខៀវ សំផន ដែល [អង្គបុរេជំនុំជម្រះ] បានចេញនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១” ហើយថា ពុំមានវិធានការណាផ្សេងទៀតពីមុនមកនៅក្នុងសំណុំរឿង ០០២ ត្រូវបានប្រកាន់យក ដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះឡើយ[39]។ ជាក់ស្តែងគឺថា វិធានការនានាដែលត្រូវបានប្រកាន់យកនៅក្នុងសំណុំរឿង ០០២ មិនត្រូវបានដឹងយ៉ាងពេញលេញទេ។

ទោះជាយ៉ាងណាក្តី ក្រៅពីកង្វះភស្តុតាងគាំទ្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ហានៅក្នុងទឡ្ហីករណ៍របស់គាត់គឺថា សំណុំរឿងទាំងពីរនេះខុសស្រឡះពីគ្នា។ នៅក្នុងសំណុំរឿង ០០២ មានដីកាដំណោះស្រាយតែមួយ ហើយត្រូវបានបញ្ជាក់ដោយសំឡេងគាំទ្រភាគច្រើនលើសលុបសម្រេចលើបណ្តឹងឧទ្ធរណ៍។ នៅក្នុងសំណុំរឿង ០០៤/២ មានដីកាដំណោះស្រាយពីរដាច់ស្រឡះពីគ្នា និងផ្ទុយគ្នា ដែលពុំមានដីកាដំណោះស្រាយណាមួយត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលុប សម្រេចទៅលើបណ្តឹងឧទ្ធរណ៍ទេ។ *ដីកាសម្រេចលើកលែងចោទប្រកាន់* មានសុពលភាពអនុលោមតាមវិធាន ៧៧(១៣)(ក)។ ទោះបី *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅ*

---

[37] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៦១។

[38] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៦២, ៦៩។

[39] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៦៣។

*ជំនុំជម្រះ)* ក៏មានសុពលភាពដែរ អនុលោមតាមវិធាន ៧៧(១៣)(ខ) ក៏ដោយ ក៏វាមិនមានឥទ្ធិពលទៅលើសុពលភាពរបស់ *ដីកាសម្រេចលើកលែងចោទប្រកាន់* ឡើយ។ ទោះបី សហព្រះរាជអាជ្ញាអន្តរជាតិ ចង់លុបបំបាត់ *ដីកាសម្រេចលើកលែងចោទប្រកាន់* តាមទំហំចិត្តរបស់គាត់ក៏ដោយ ក៏គាត់មិនអាចធ្វើបែបនេះបានទេ។ ដីកានេះ និងយោបល់របស់ចៅក្រមភាគច្រើននៃ អង្គបុរេជំនុំជម្រះ មិនអាចមិនយកចិត្តទុកដាក់ ឬទុកចោលបានឡើយ ហើយការសន្និតរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អំពីវិធានការនានានៅក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងការទទួលយកសំណុំរឿងដោយ អង្គជំនុំជម្រះសាលាដំបូង និង ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ មិនគ្រប់គ្រាន់ដើម្បីបង្ហាញអំពីកំហុសអង្គច្បាប់ ឬការបំពានឆន្ទានុសិទ្ធិបានឡើយ។

**ច. អង្គជំនុំជម្រះសាលាដំបូងមិនបាន "រំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ផ្អែកលើទឡ្ហីករណ៍ដែលមិនអាចអនុញ្ញាតបាន" នោះឡើយ ហេតុនេះ ពុំបានប្រព្រឹត្តកំហុសអង្គច្បាប់ក្នុងចំណុចនេះទេ**

អង្គជំនុំជម្រះសាលាដំបូង មិនបានរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយផ្អែកលើ "ទឡ្ហីករណ៍ដែលមិនអាចអនុញ្ញាតបាន" នោះឡើយ[40]។ ការពិត អង្គជំនុំជម្រះមិនបានរំលត់សំណុំរឿងនេះដោយផ្អែកលើទឡ្ហីករណ៍ណាឡើយ ដោយសារពុំមានសំណុំរឿងអ្វីដែលត្រូវរំលត់ទេ។ សំណុំរឿង ០០៤/២ ត្រូវបានរំលត់ជាធរមាននៅពេល អង្គបុរេជំនុំជម្រះ ចេញ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* របស់ខ្លួន ដែលមានអានុភាពជាអាជ្ញាអស់ជំនុំ ដោយសារវាជាសេចក្តីពិចារណាស្ថាពរ និងបិទផ្លូវតវ៉ា[41]។ ដូចដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានកត់សម្គាល់នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនគឺថា អាជ្ញាអស់ជំនុំ គឺជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋាននានាដែល

[40] *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៧១-៧៦។

[41] *រឿងក្តី Kajelijeli ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿង ICTR-98-44A-A *សាលក្រម* ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ២០២ ("ទ្រឹស្តីនេះសំដៅដល់ស្ថានភាពមួយដែល "សាលក្រមស្ថាពរលើអង្គសេចក្តី" ត្រូវបានចេញដោយតុលាការមានការសមត្ថកិច្ច ដោយផ្អែកលើបណ្តឹងស្នើសុំ បណ្តឹងទាមទារ ឬមូលហេតុសកម្មភាពរវាងភាគីនានា បង្កើតជារបាំងដាច់ខាតមិនឱ្យមាន "បណ្តឹងលើកទីពីរទៅលើការអះអាងតែមួយ" រវាងភាគីដដែល")។ *សូមមើល រឿងក្តី Zolotukhin ទល់នឹង ប្រទេសរុស្ស៊ី* (ពាក្យសុំលេខ 14939/03) តុលាការ ECtHR *សាលក្រម* ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ១០៧ (សេចក្តីសម្រេចមួយជាស្ថាពរ "ប្រសិនបើតាមការសំដែងមតិតាមបែបប្រពៃណី វាមានកម្លាំងជាអាជ្ញាអស់ជំនុំ។ ករណីនេះជាការពិត នៅពេលវាពុំអាចបកស្រាយបានថា នៅពេលពុំមានដំណោះស្រាយធម្មតាថែមទៀតដែលមាន ឬនៅពេលភាគីបានប្រើប្រាស់ដំណោះស្រាយទាំងអស់រួចហើយ ឬបានបណ្តោយឱ្យពេលវេលាកំណត់ កន្លងផុតទៅដោយមិនប្រើប្រាស់ដំណោះស្រាយទាំងនោះ")។ *បញ្ហានានានៃការកំណត់ព្រំដែននៃទ្វេនាប់ទ្វីបរវាងប្រទេសនីការ៉ាហ្គា និង ប្រទេសកូឡុំប៊ី ហួសពីចម្ងាយ ២០០ ម៉ៃល៍នីកូទីកា ពីឆ្នេរសមុទ្រនីការ៉ាហ្គា (រឿងក្តី ប្រទេសនីការ៉ាហ្គា ទល់នឹង ប្រទេសកូឡុំប៊ី) អញ្ញត្រកម្ម សាលក្រម* តុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨-៦០ ("តុលាការសូមរម្លឹកថា គោលការណ៍អាជ្ញាអស់ជំនុំ [...] គឺជាគោលការណ៍ច្បាប់ទូទៅដែល នៅពេលជាមួយគ្នានោះ វាការពារដំណើរការរបស់តុលាការ ឬសាលាក្តី និងភាគីនៅក្នុងរឿងក្តីដែលនាំឱ្យមានសាលក្រមដែលស្ថាពរ និងគ្មានការប្តឹងជំទាស់")។

បណ្តឹងអាជ្ញាអាចត្រូវរលត់ក្រោមច្បាប់កម្ពុជា[42]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង មិនបានប្រព្រឹត្តកំហុសអង្គច្បាប់ក្នុងចំណុចនេះទេ។

យោងតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តាកុំពិចារណាទៅលើ *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ដោយសារអង្គជំនុំជម្រះពុំបានទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យតាមផ្លូវច្បាប់ទេ ហេតុនេះអង្គជំនុំជម្រះពុំមានសិទ្ធិអំណាចក្នុងការទទួលយកទឡ្ហីករណ៍ និងសំណើនានានៅក្នុងបណ្តឹងសាទុក្ខនេះមកពិនិត្យឡើយ។ ជាងនេះទៀត ឬជាជម្រើសម្យ៉ាងទៀត អនុលោមទៅតាមសំអាងហេតុនានាដែលបានលើកឡើងនៅក្នុងចម្លើយតបនេះ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូល មេត្តាប្រកាសថា *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ពុំអាចទទួលយកបាន ហើយមូលដ្ឋាននានានៃបណ្តឹងសាទុក្ខដែលបានចោទប្រកាន់នេះពុំមានខ្លឹមសារអ្វីឡើយ។

ធ្វើនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា

សហមេធាវីការពារក្តីលោក អោ អាន

| | | |
|---|---|---|
| មុំ លុជ្ស | Richard ROGERS | Goran SLUITER |

42 *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៧៤។